## ១. សេចក្តីផ្តើម

ចរន្ត នៃការវិវឌ្ឍននយោបាយលើសកលលោក នាំឱ្យប្រទេសកាន់តែច្រើនឡើងៗ មាននិន្នាការងាកមកប្រកាន់យករបបគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យពហុបក្សអាស្រ័យសភា និងសេដ្ឋកិច្ចទីផ្សារសេរី។

តាមការសិក្សាអំពីសភាជាន់ខ្ពស់ជាច្រើនកន្លងមកនេះ ពុំទាន់ឃើញអ្វីជាគំរូសម្រាប់ការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃសភាទាំងនេះទេ។ លក្ខណៈប្លែកៗគ្នាអាស្រ័យទៅតាមរដ្ឋនិមួយៗជ្រើសរើសយកដោយយល់ទៅតាមស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររៀងៗខ្លួន ហើយសភាជាន់ខ្ពស់តែងមានការប្រែប្រួលពីជំណាក់មួយទៅជំណាក់កាលមួយដោយឥតឈប់ឈរ។ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅនេះជម្រើសមួយដ៏ល្អ និងមានសារៈសំខាន់ក្នុងការជួយឱ្យដំណើរការ នៃការគ្រប់គ្រងរដ្ឋប្រព្រឹត្តទៅបានរលូនល្អប្រពៃ និងមានតម្លាភាពនោះគឺការកាន់យករបបសភាពីរ មានន័យថាស្ថាប័ននីតិប្បញ្ញត្តិត្រូវចែកចេញជាពីរផ្នែកមានព្រឹទ្ធសភា ឬសភាជាន់ខ្ពស់ផង និងមានរដ្ឋសភា ឬសភាជាន់ទាបផងដែរ។

ជម្រើសនេះបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់ក្នុងការកសាងច្បាប់សម្រាប់បម្រើអោយការគ្រប់គ្រងសង្គមបានគ្រប់គ្រាន់ និងប្រកបដោយគុណភាព ដោយសារដំណើរការនៃការពិនិត្យ និងអនុម័តច្បាប់ប្រព្រឹត្តទៅបានល្អគ្រប់ជ្រុងជ្រោយ ល្អិតល្អន់ និងមានភាពសុក្រឹតធ្វើអោយការអនុវត្តច្បាប់មានប្រសិទ្ធភាពខ្ពស់ ជាកត្តាជម្រុញអោយប្រទេសជាតិឆ្ពោះទៅកាន់នីតិរដ្ឋយ៉ាងឆាប់រហ័ស។

និន្នាការ នៃការអនុវត្តរបបសភាពីរថ្នាក់នេះ មានការរីកចំរើនជាលំដាប់ឥតឈប់ឈរ មកទល់នឹងពេលបច្ចុប្បន្ននៅលើសកលលោក មានប្រទេសចំនួន៧៧ ដែលជ្រើសរើសយកការអនុវត្តន៍ប្រព័ន្ធសភាពីរថ្នាក់នេះ។ ក្នុងចំនោមប្រទេសទាំងនោះព្រឹទ្ធសភា នៃប្រទេសចំនួន៣៩ កើតឡើងដោយការបោះឆ្នោត និង២១ប្រទេសកើតឡើងដោយការបោះឆ្នោតផង និងតែងតាំងផង ហើយព្រឹទ្ធសភា នៃប្រទេសចំនួន១៧ទៀតកើតឡើងដោយការតែងតាំង។ ទម្រង់ នៃការបោះឆ្នោតមានលក្ខណៈខុសៗគ្នាគឺប្រទេសខ្លះអនុវត្តប្រព័ន្ធបោះឆ្នោតជាសកល ខ្លះអសកល ហើយខ្លះទៀតអនុវត្តប្រព័ន្ធបោះឆ្នោតចម្រុះ។ ម្យ៉ាងទៀតការរៀបចំ និងការប្រព្រឹត្តទៅ នៃស្ថាប័នព្រឹទ្ធសភា ក៏មានលក្ខណៈខុសគ្នាអាស្រ័យទៅតាមប្រទេសនីមួយៗផងដែរ។ ប្រទេសខ្លះបានចែងកំណត់ច្បាស់លាស់នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋតែម្តង ហើយប្រទេសខ្លះទៀតរដ្ឋធម្មនុញ្ញគ្រាន់តែចង្អុលទិសប៉ុណ្ណោះ រីឯការកំណត់លម្អិតជាក់លាក់ត្រូវយកទៅចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងផ្ទាល់របស់ស្ថាប័នព្រឹទ្ធសភាវិញ។

## ២. ប្រវត្តិព្រឹទ្ធសភា

ប្រព័ន្ធសភាពីរថ្នាក់ បានកើតឡើងនៅក្នុងប្រទេសកម្ពុជា តាំងពីពេលដែល រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានកកើតឡើងជាលើកដំបូង នាឆ្នាំ១៩៤៧។ ប៉ុន្តែអាស្រ័យដោយឥទ្ធិពលនៃសង្គ្រាមត្រជាក់ លើសកលលោក បានធ្វើឱ្យប្រទេសកម្ពុជា ត្រូវធ្លាក់ចូលទៅក្នុងសង្គ្រាមរ៉ាំរ៉ៃអស់រយៈពេលជាងពីរទសវត្សរ៍ ដែលបានធ្វើឱ្យគ្រប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ត្រូវបំផ្លាញខ្ទេចខ្ទី និងបាត់បង់ទាំងស្រុងធ្លាក់ដល់កម្រិតសូន្យ នាសម័យកាលដ៏ខ្មៅងងឹត នៃរបបកម្ពុជាប្រជាធិបតេយ្យ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានកំណត់ឱ្យមានការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌ក្នុងប្រទេសកម្ពុជា ក្រោមការរៀបចំរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំ នៅកម្ពុជាហៅកាត់ថា (UNTAC) ដើម្បីបញ្ចប់ជម្លោះបង្កើតស្ថាប័នគ្រប់គ្រងប្រទេស និងកសាងនីតិរដ្ឋ។

បន្ទាប់ពីការបោះឆ្នោតជាសកលលើកដំបូង ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញមួយបានចាប់បដិសន្ធិឡើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញនោះ ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងបានចូលជាធរមាន នាថ្ងៃទី២៤ ខែឆ្នាំដដែល។ រដ្ឋធម្មនុញ្ញនោះ បានកំណត់ឱ្យព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

អំណាចក្នុងការគ្រប់គ្រងរដ្ឋ ត្រូវបានបែងចែកដាច់ពីគ្នាជាបី គឺអំណាច នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ នៅពេលរដ្ឋធម្មនុញ្ញបានចូលជាធរមាន សភាធម្មនុញ្ញបានក្លាយទៅជារដ្ឋសភានីតិកាលទី១ ហើយបានដំណើរការក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិតែមួយគត់ របស់ព្រះរាជាណាចក្រកម្ពុជាពេញមួយ នីតិកាល។

ក្រោយការបោះឆ្នោតជាសកល ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ វិបត្តិនយោបាយ ផ្ទៃក្នុងមួយបានកើតឡើង។ ដើម្បីដោះស្រាយវិបត្តិនេះ កិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃគណបក្សនយោបាយធំទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចបានប្រារព្ធឡើងពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ** ដែលនៅពេលនោះព្រះអង្គទ្រង់ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈលទ្ធផលនៃកិច្ចប្រជុំកំពូលនេះ ស្ថាប័នព្រឹទ្ធសភា ត្រូវបានបង្កើតឡើង និងក្លាយជាចំណែកមួយនៃស្ថាប័ននីតិប្បញ្ញត្តិជាតិ ដែលមានពីរថ្នាក់ បន្ទាប់ពីរដ្ឋធម្មនុញ្ញនីតិកាលទី២ បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំង និងមានអាណត្តិ៥ឆ្នាំ។ សមាជិកចំនួន៦១រូប ត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជនជាន់ខ្ពស់ នៃគណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភានីតិកាលទី២។

ព្រឹទ្ធសភា នីតិកាលទី១ បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ព្រឹទ្ធសភានីតិកាលទី២ កើតឡើងដោយការបោះឆ្នោតជាអសកល នាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ ដោយមានអាណត្តិ៦ឆ្នាំ។ ក្នុងចំណោម សមាជិក៦១រូប មាន៥៧រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល ០២រូបជ្រើសតាំងដោយរដ្ឋសភា និង០២រូបតែងតាំងដោយព្រះមហាក្សត្រ។

ព្រឹទ្ធសភានីតិកាលទី២ បានបើកសម័យប្រជុំដំបូង នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ដោយមានអាណត្តិ៦ឆ្នាំ។ ក្នុងចំណោមសមាជិក ៦១រូប មាន ៥៧រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល ០២រូបជ្រើសតាំងដោយរដ្ឋសភា និង០២រូបតែងតាំងដោយព្រះមហាក្សត្រ។

ព្រឹទ្ធសភានីតិកាលទី៣ បានបើកសម័យប្រជុំដំបូង នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ដោយមានអាណត្តិ ៦ឆ្នាំ ដូចព្រឹទ្ធសភា នីតិកាលទី២ ដែរ។ ក្នុងចំណោមសមាជិកព្រឹទ្ធសភាទាំងអស់មាន ៦១រូប មាន ៥៧រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល ០២រូបជ្រើសតាំងដោយរដ្ឋសភា និង ០២ រូបទៀតតែងតាំងដោយព្រះមហាក្សត្រ ។

## ៣. មុខងារព្រឹទ្ធសភា

*១/. <u>មុខងារនីតិកម្ម៖</u>* ពិនិត្យអោយយោបល់លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា និងផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់។ តួនាទីសំខាន់របស់ព្រឹទ្ធសភា គឺការពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។ រដ្ឋសភាមិនអាចបញ្ជូនច្បាប់ដែលខ្លួនបានអនុម័តរួចហើយអោយព្រះមហាក្សត្រឡាយព្រះហស្ថលេខា ប្រកាសអោយប្រើជាផ្លូវការមុនពេលដាក់ឆ្លងអោយព្រឹទ្ធសភាពិនិត្យបានឡើយ។ ព្រឹទ្ធសភាមានអំណាចត្រួតពិនិត្យព្រមទាំងធ្វើអនុសាសន៍ទៅលើពង្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភា។ ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬស្នើអោយធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំអោយរដ្ឋសភាទទួលយកអនុសាសន៍របស់ខ្លួនឡើយ។ ចំណែកឯរដ្ឋសភាវិញ អាចបដិសេធមិនទទួលអនុសាសន៍របស់ព្រឹទ្ធសភា ហើយនឹងអាចអនុម័តអោយចេញនូវច្បាប់ដែលព្រឹទ្ធសភាបានបដិសេធ។ច្បាប់ណាក៏ដោយ បើទោះបីជាព្រឹទ្ធសភាបដិសេធតែទីបំផុតនៅតែត្រូវបានរដ្ឋសភាអនុម័ត ហើយដាក់ថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្ថលេខា និងប្រកាសអោយប្រើ។ រដ្ឋធម្មនុញ្ញមិនបានផ្តល់អោយព្រឹទ្ធសភានូវអំណាចអនុម័តនូវច្បាប់ ឬអំណាចជំទាស់អត្ថបទច្បាប់ឡើយប៉ុន្តែផ្តល់អោយនូវតួនាទីប្រឹក្សា ឬអំណាចធ្វើអនុសាសន៍ដែលរដ្ឋសភាបានអនុម័ត។

ព្រឹទ្ធសភាសហការជាមួយរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីរៀបចំអោយបានចេញជារូបរាងនូវកម្មវិធី និងប្រតិទិននៃការកសាងច្បាប់សម្រាប់ឆ្នាំនីមួយៗ។

ព្រឹទ្ធសភាផ្តល់យោបល់លើអត្ថបទច្បាប់ក្នុងរយៈពេលមួយខែយ៉ាងយូរដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់បើជាការប្រញាប់អោយពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាអោយយោបល់ព្រម ឬពុំបានអោយយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ។

ព្រឹទ្ធសភាមានអំណាចចំពោះការផ្តួចផ្តើមធ្វើច្បាប់ និងអនុម័តប៉ុន្តែមិនមានអំណាចសម្រេចជាចុងក្រោយថាតើច្បាប់ទាំងនោះចូលជាធរមាន ឬអត់នោះទេ។ មានតែរដ្ឋសភាមួយគត់ ដែលមានអំណាចនោះ។ មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ ផ្តល់អំណាចនេះអោយទៅព្រឹទ្ធសភាដោយចែងថា «សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់»។

ចំពោះការកែសម្រួល ឬបដិសេធច្បាប់ព្រឹទ្ធសភាមានសិទ្ធិសុំអោយកែសម្រួល ឬបដិសេធអត្ថបទច្បាប់នោះ ក្នុងករណីនេះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេច

តែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំអោយកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

*២/. __មុខងារត្រួតពិនិត្យ៖__* ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តន៍គោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលជាពិសេសត្រួតពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល។

២.១/ កម្មវត្ថុនៃការត្រួតពិនិត្យ៖

__២.១.១ការអនុវត្តន៍ច្បាប់៖__ព្រឹទ្ធសភាដើរតួនាទីសំខាន់ ក្នុងការតាមដានដំណើរការការងាររបស់ស្ថាប័នរដ្ឋ និងត្រួតពិនិត្យយ៉ាងទៀងទាត់អំពីការ អនុវត្តន៍ច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។

__២.១.២ការអនុវត្តន៍កម្មវិធីនិងផែនការរបស់រាជរដ្ឋាភិបាល៖__ ព្រឹទ្ធសភាក៏ដើរតួនាទីសំខាន់ក្នុងការអនុវត្តន៍នូវកម្មវិធីនិងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ នីតិរដ្ឋ ការងារ កែទម្រង់រដ្ឋ ការងារកាត់បន្ថយភាពក្រីក្រ ការងារ អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។

២.២ វិធីត្រួតពិនិត្យ៖

__២.២.១ចុះរកព័ត៌មានតាមមូលដ្ឋានក្រសួង៖__ព្រឹទ្ធសភាប្រមូលបញ្ហារសើបពីប្រភពផ្សេងៗតាមរយៈឯកសារអនាមិកជួបសម្ភាសន៍អ្នកឯកទេសពាក់ព័ន្ធ សិក្សាវិភាគលើទិដ្ឋភាពផ្សេងៗ ឯកសារយោងបទដ្ឋានគតិយុត្តិ ឬសំណុំរឿងប្រហាក់ប្រហែលសហការជាមួយអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងប្រជាពលរដ្ឋ ដល់ទីកន្លែង។

__២.២.២ អញ្ជើញតំណាងរាជរដ្ឋាភិបាលមកបំភ្លឺ៖__ ប្រសិនបើឃើញថាមានការខ្វះខាតលើអត្ថបទច្បាប់ណាមួយព្រឹទ្ធសភាអាចស្នើសុំអោយរាជរដ្ឋាភិបាល ឬរដ្ឋមន្ត្រីពាក់ព័ន្ធមកបំភ្លឺ និងអាចផ្តល់ជាអនុសាសន៍កែលំអរឡើងវិញក្នុងន័យស្ថាបនា។

__២.២.៣ ពិនិត្យលើរបាយការណ៍សកម្មភាពដែលរាជរដ្ឋាភិបាល ឬក្រសួងផ្ញើមក៖__ ព្រឹទ្ធសភាដើរតួនាទីសំខាន់ក្នុងការតាមដានលើរបាយការណ៍សកម្មភាពរបស់រាជរដ្ឋាភិបាល ឬរបស់ក្រសួងដើម្បីទទួល បាននូវព័ត៌មានដ៏សំខាន់។ ករណីនេះបើសិនជាព្រឹទ្ធសភា ពិនិត្យលើរបាយការណ៍ឃើញថាមានការខ្វះចន្លោះ ឬចំណុចខ្សោយត្រង់ណានោះ ព្រឹទ្ធសភាអាចធ្វើជារបាយការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីផ្តល់ជាយោបល់កែលំអរ និងជាការរួមចំណែកក្នុងយន្តការស្ថាបនាចំណុចខ្វះខាតនោះអោយមានលក្ខណៈល្អឡើងវិញ។

*៣/. __មុខងារជាតំណាង៖__*

៣.១. __តំណាងសមូហភាពដែនដី (ក្រុមប្រឹក្សាឃុំ-សង្កាត់)៖__ ព្រឹទ្ធសភាតំណាងអោយភូមិភាគ និងសមូហភាពដែនដី (ក្រុមប្រឹក្សាឃុំ-សង្កាត់) មាត្រា៩ និងមាត្រា១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បានបង្ហាញច្បាស់អំពីអត្តសញ្ញាណរបស់សមាជិកព្រឹទ្ធសភា។ ក្នុងតួនាទីជាអ្នកតំណាង អោយក្រុមប្រឹក្សាឃុំសង្កាត់ដែលជាស្ថានតភ្ជាប់នូវកិច្ចទំនាក់ទំនងរវាងមូលដ្ឋាន

ដែនដី និងរាជរដ្ឋាភិបាលព្រឹទ្ធសភាចាំបាច់ត្រូវតែផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើផលប្រយោជន៍របស់ក្រុមប្រឹក្សា ឃុំ-សង្កាត់ និងភូមិភាគ។
បន្ទាប់ពីការបោះឆ្នោតជាអសកលលើកដំបូងដើម្បីជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ មកព្រឹទ្ធសភាមានទម្ងន់នយោបាយមួយតាមរយៈការពង្រឹងដំណើរការពិនិត្យតាមដានការអនុវត្តន៍គោល នយោបាយវិមជ្ឈការ វិសហមជ្ឈការក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០២មក។ បច្ចុប្បន្នក្នុងចំនួនប្រជាជនសរុបជាង ១៤លាននាក់ ត្រូវតំណាងអោយឃុំសង្កាត់ ចំនួន ១៦២១ ក្នុងនោះមានសមាជិកក្រុម ប្រឹក្សាឃុំ-សង្កាត់ សរុបចំនួន ១១៣៥៣នាក់ ដែលត្រូវបានប្រជាជនផ្តល់នូវជំនឿទុកចិត្ត និងសេចក្តីសង្ឃឹមជឿជាក់។ ដូច្នេះព្រឹទ្ធសភាគឺជាចំណុចប្រសព្វនៃដំណើរការជ្រើសរើសសម្រិតសម្រាំង និងភាពជំរុញដោយហេតុផល។

៣.២. <u>តំណាងស្ថាប័នជាតិ៖</u> សមាជិក ០២រូប តែងតាំងដោយព្រះមហាក្សត្រ និង០២រូបទៀតតែងតាំងដោយរដ្ឋសភា។ ព្រឹទ្ធសភាក៏តំណាងអោយព្រះមហាក្សត្រ និងរដ្ឋសភា ហើយក៏ជាអ្នកសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលមាត្រា ១១២ បញ្ជាក់ថា «ព្រឹទ្ធសភាមានភារកិច្ចសម្រប សម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល»។ នេះបើតាមទ្រឹស្តី ជាតួនាទីមួយដែលសំខាន់បំផុតដែលអនុញ្ញាតអោយព្រឹទ្ធសភា អនុវត្តនូវឥទ្ធិពលមួយសំខាន់លើការងាររបស់ស្ថាប័នទាំងពីរ គឺរាជរដ្ឋាភិបាល និងរដ្ឋសភា។ ប៉ុន្តែតួនាទីនេះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពទេ។ មាត្រា១១២ចែងតែគោលការណ៍ដោយមិនបញ្ជាក់ពីសារធាតុដែលមាននៅក្នុងនោះទេ។ ក្រុមប្រឹក្សាធម្មនុញ្ញក៏មិនបានបញ្ជាក់អោយច្បាស់ជាងនេះដែរ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនេះគ្រាន់តែបញ្ជាក់ថាវាគ្រាន់តែជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ដែលមិនអាចកំណត់បានដោយអត្ថបទច្បាប់ ឬបទបញ្ញាណាមួយបានទេ។ ព្រឹទ្ធសភា ត្រូវតែប្រើប្រាស់គ្រប់មធ្យោបាយ និងអាចធ្វើអន្តរាគមន៍បានគ្រប់ពេលវេលា ដើម្បីដោះស្រាយវិបត្តិនយោបាយ តូច ឬធំរវាងស្ថាប័នទាំងពីរ។ ព្រឹទ្ធសភាមិនអាចបង្ខំទស្សនៈរបស់ខ្លួនអោយរដ្ឋសភា និងរាជរដ្ឋាភិបាលគោរពតាមដោយឆន្ទានុសិទ្ធិបានទេ។ និយាយផ្សេងពីនេះ ទៀតតួនាទីនេះមិនចងស្ថាប័នទាំងពីរនេះទេ។ ចុងបញ្ចប់សេចក្តីសម្រេចក្រុម ប្រឹក្សាធម្មនុញ្ញនេះបញ្ជាក់ថា តួនាទីនេះ ចាត់ទុកថាមានលទ្ធផលវិជ្ជមាន នៅពេលដែលមានការស្រុះស្រួលគ្នា រវាងស្ថាប័នទាំងពីរ។

៣.៣. <u>តំណាងប្រជាជាតិទាំងមូល៖</u> សមាជិកព្រឹទ្ធសភាភាគច្រើន ត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតជាអសកលមិនចំពោះ និងតាមវិធីជ្រើសរើស បោះឆ្នោតជាសម្ងាត់ តំណាងអោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលប្រមូលផ្តុំនៅក្នុងភូមិភាគទាំង៨។ ព្រឹទ្ធសភាមានកាតព្វកិច្ចចូលរួម ចំណែកយ៉ាងខ្ជាប់ខ្ជួនក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងជួយផ្តល់អនុសាសន៍ដើម្បីតម្រង់ទិស លើការអនុ-វត្តន៍ ជាក់ស្តែងអោយបានប្រកបដោយលទ្ធផលផ្លែផ្កាពិតប្រាកដដល់ឃុំសង្កាត់ទូទាំងប្រទេស និងភូមិភាគ។ ប្រការនេះមានការពាក់ព័ន្ធ ដល់ការដ្ឋាន ដ៏ធំដែល រាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែង ក្នុងការកែទម្រង់ការគ្រប់គ្រង រដ្ឋបាលសាធារណៈ និងការបង្កើតប្រជាធិបតេយ្យអោយទៅដល់ថ្នាក់មូលដ្ឋានជិតប្រជាជន នោះគឺជាការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដើម្បី អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ៤. តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភា ជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិរបស់ជាតិ ដែលបានរួមចំណែកក្នុងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មសង្គម និងការកសាងកម្ពុជាជានីតិរដ្ឋ ហើយបានរួមវិភាគទាននៅក្នុងដំណើរការស្ថេរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិ ដែលជាស្នូលនៃការពង្រឹងនយោបាយ បង្រួបបង្រួម ផ្សះផ្សាជាតិ និងការអភិវឌ្ឍ។ ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញមាត្រា១១២ថ្មី)។ ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេល ដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅ ប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភា ត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះរយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់រដ្ឋសភាមិនអាច នឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវ បានយកទៅប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា១១៣ថ្មី)។

## ៥. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

**<u>ការរៀបចំ</u>**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអង្គការដឹកនាំកំពូលរបស់ព្រឹទ្ធសភា ដឹកនាំដោយប្រធានព្រឹទ្ធសភា ហើយមានអនុប្រធានទាំងពីរ និងប្រធានគណកម្មការនានារបស់ព្រឹទ្ធសភាជាសមាជិក។

ព្រឹទ្ធសភាមានគណៈកម្មការនានាចំនួន១០ ៖

១-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ
៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍
៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
៩-គណៈកម្មការ សាធារណៈការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១០-គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ។

*__សម្គាល់__*៖ គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ជាគណៈកម្មការថ្មី កើតឡើងតាមរយៈការធ្វើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣ ដែលប្រកាសឲ្យប្រើតាមសេចក្តីសម្រេចលេខ ០៩១/០៩១៤/ពស.សរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ ដោយយោងតាមស្មារតី នៃកិច្ចព្រមព្រៀងស្តីពីការរៀបចំ ឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ និងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ។

__ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា__

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ ហើយសម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិច៣ខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួន មួយភាគបីយ៉ាងតិចព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ (មាត្រា១០៧ថ្មី នៃរដ្ឋធម្មនុញ្ញ)។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ។ កំណត់ហេតុទាំងអស់ត្រូវរក្សាទុកនៅក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា។

ព្រឹទ្ធសភា អាចកោះប្រជុំជាសម្ងាត់បានតាមសំណើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយ ភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា (មាត្រា១១១ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ)។ ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមាន ៖

ក- កូរ៉ុមលើសពីពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬមតិភាគច្រើនដាច់ខាតនៃចំនួន សមាជិកព្រឹទ្ធសភាទាំងមូល។

កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល៣០នាទី ក្រោយពេលកំណត់ចាប់ផ្តើមការប្រជុំ ប្រធានព្រឹទ្ធសភា ត្រូវលើកពេលប្រជុំ (ប្រការ៤១ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

## ៦. ស្ថានភាពបច្ចុប្បន្នរបស់ព្រឹទ្ធសភាកម្ពុជា

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ ២០០៦ បានធ្វើការអោយតួនាទីរបស់ព្រឹទ្ធសភាកាន់តែ ទូលំទូលាយ ឡើងថែមទៀត ក្នុងតួនាទីជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំង ប្រទេស ដែលកំពុង អនុវត្តនូវ គោលវិមជ្ឈការ និងវិសហមជ្ឈការ។ បច្ចុប្បន្ននេះការអភិវឌ្ឍស្ថាប័នកាន់តែមានសារៈសំខាន់ ប៉ុន្តែនៅមានបញ្ហាមួយចំនួនក្នុងការអនុវត្តភារកិច្ច របស់ខ្លួនដោយសារតែ ៖

ក-ការពិនិត្យអត្ថបទច្បាប់ (សេចក្តីព្រាងច្បាប់ភាគច្រើន គឺជាគំនិតផ្តួចផ្តើមរបស់នីតិប្រតិបត្តិដូចជាប្រទេស ប្រកាន់លិទ្ធប្រជាធិបតេយ្យផ្សេងទៀតដែរ) ពុំទាន់មានធនធាន និងស្តង់ដារគ្រប់គ្រាន់ក្នុងដំណើរការនិតិវិធី។ ធនធានដែលគណៈកម្មការជំនាញអាចប្រើបាននៅមានកម្រិត ទាំងផ្នែកស្រាវជ្រាវឯកសារ និងការផ្តល់យោបល់បច្ចេកទេស។ កាងារវិមជ្ឈការ វិសហមជ្ឈការដែលរដ្ឋបានអនុវត្តតាំងពីឆ្នាំ ២០០២កំពុងប្រព្រឹត្ត បន្តទន្ទឹមនឹងការបន្ត កសាងច្បាប់ និងបទដ្ឋានចាំបាច់នានា។ វេទិកាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិលនិងអង្គការក្រៅរដ្ឋាភិបាលពុំទាន់បានរៀបចំជាប្រព័ន្ធនៅឡើយ ។

ខ-ក្នុងឋានៈជាស្ថាប័នដែលមានតួនាទីតាមដានការងាររបស់រាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភាមានកិច្ចការច្រើនពាក់ព័ន្ធជាចម្បងទៅនឹងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាននានា ដែលត្រូវឆ្លើយឆ្លងគ្នាជាមួយរាជរដ្ឋាភិបាល និងត្រូវចុះពិនិត្យស្រាវជ្រាវជាក់ស្តែង។ប៉ុន្តែដោយសារការពិនិត្យអត្ថបទច្បាប់ជាបន្ទុកធ្ងន់ធ្ងរគណៈកម្មការជំនាញមិនអាចចំណាយពេលបានច្រើនឡើយ។ ច្បាប់មួយចំនួនដែលបានអនុម័តមិនទាន់បានអនុវត្តទាំងស្រុងដោយសារការផ្សព្វផ្សាយច្បាប់នោះនៅមានកម្រិត ហើយការកសាងលិខិតបទដ្ឋាន បន្ថែមដើម្បី អនុវត្ត ច្បាប់របស់រាជរដ្ឋាភិបាលពុំបានធ្វើទាន់ពេលវេលា។

គ- ក្នុងឋានៈជាតំណាងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់សមាជិកព្រឹទ្ធសភាខ្វះធនធាន និងមធ្យោបាយធ្វើដំណើរទៅកាន់ភូមិភាគដើម្បីផ្សព្វផ្សាយពីសកម្មភាព និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយថ្នាក់មូលដ្ឋានឱ្យឆ្លើយតបតាមការរំពឹងទុករបស់សាធារណជន។ ក្នុងបរិបទនេះ ព្រឹទ្ធសភាត្រូវតែអភិវឌ្ឍន៍ការិយាល័យព្រឹទ្ធសភា តាមភូមិភាគ ។ គោលបំណងចម្បងនៃការ រៀបចំនេះ គឺដើម្បីតាមដានការវិវឌ្ឍក្នុងក្របខ័ណ្ឌឃុំ/សង្កាត់ និងទទួលពាក្យបណ្តឹងពីពលរដ្ឋនៅតាម ភូមិភាគទាំងនោះ ដែលត្រូវបញ្ជូនមកព្រឹទ្ធសភាដោយផ្ទាល់ ដើម្បីមានវិធានការតាមនីតិវិធី។

## ៧. សន្និដ្ឋាន

ក្រោយពីការបង្កើតស្ថាប័នព្រឹទ្ធសភានៅឆ្នាំ១៩៩៩ ព្រះរាជាណាចក្រកម្ពុជាមានស្ថាប័ននីតិប្បញ្ញត្តិពីរដែលក្នុងនោះ ស្ថាប័នព្រឹទ្ធសភា ជាស្ថាប័នកំពូលដែលបានចូលរួមពង្រឹងវិស័យច្បាប់នៅកម្ពុជា ដោយរាល់សេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់អនុម័តនៅរដ្ឋសភារួចហើយត្រូវបញ្ជូនទៅព្រឹទ្ធសភា ដើម្បីផ្តល់យោបល់ ឬនិងកែសម្រួល។ ក្នុងរយៈពេលកន្លងមកនេះ ស្ថាប័នព្រឹទ្ធសភាសម្រេចបានគោលដៅ និងសមិទ្ធិផលជាច្រើនក្នុងការរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ជាពិសេសគឺការពង្រឹងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។ យ៉ាងណាមិញដើម្បីជម្រុញប្រសិទ្ធភាពការងារ ស្ថាប័នព្រឹទ្ធសភាបានប្រឹងប្រែងពង្រឹងសមត្ថភាពតាមរយៈការអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលទាំងនេះជាការឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋជាស្នូល។

សមិទ្ធិផល និងភាពជោគជ័យរបស់ព្រឹទ្ធសភាអាចវាស់វែងបានតាមរយៈធ្វើអោយប្រសើរឡើងនៃប្រសិទ្ធភាពការងារ និងការអនុវត្តមុខងារទាំងបីគឺៈ ១. ប្រសិទ្ធភាពនៃមុខងារតាក់តែងច្បាប់ ២. ប្រសិទ្ធភាពនៃមុខងារតាមដាន ៣. ប្រសិទ្ធភាពនៃមុខងារជាតំណាង។

ជាក់ស្តែងណាស់ព្រឹទ្ធសភាជាស្ថាប័នកំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានបំពេញភារកិច្ច និងបេសកកម្មរបស់ខ្លួនទទួលបានជោគជ័យនាពេលកន្លងមកនេះ។យ៉ាងណាមិញដើម្បីពង្រឹង និងលើកកម្ពស់ប្រសិទ្ធសភាព ការងាររបស់ព្រឹទ្ធសភាកម្ពុជា និងឈានដល់កម្រិតស្តង់ដារនៃការងារប្រជាធិបតេយ្យក្នុងតំបន់ និងលើពិភពលោក ព្រឹទ្ធសភាគួរផ្តោតការយកចិត្តទុកដាក់ ចំនុចខ្វះខាតផងដែរទាំងស្ថាប័នព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

# នីតិវិធីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង



# រចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



# អង្គការលេខរបស់ព្រឹទ្ធសភា

